


# កាលគន្ធ័នប្រលោមនាងកាកី

## បទកាកគតិ

កាលក្រោយគ្រុឌទៅ គន្ធ័ននោះនៅ ឯក្រោយប្រែប្រាណ
ជាគន្ធព្វ នាងកាកីបាន យល់គន្ធ័នរាន
រុករួសមកដល់។

នាងនឹកថៃថា នេះសម្រព្រះមហា ក្សត្រក្សាន្តថ្កើងថ្កល់
ប្រើមករកអញ គួរអញធ្វើកល ឱ្យគន្ធ័នយល់
ជាអញព្រួយចិត្ត។

គិតស្រេចនាងថា ឱះឱភ័ព្វជា ថ្ងៃនេះពេកក្លាត់
ជួបបងគន្ធ័ន ប្អូនគ្រាន់ស្បើយចិត្ត បងអើយចក្រវិត្ត
ម្ល៉េះទុក្ខកន្លង។

បងអើយបងស្ងួះ បងស្វែងរូតរះ រួសរកប្អូនហោង
បងមកឯងឬ ស្ដេចប្រើប្រាណបង បងដឹងទំនង
ឬគេប្រាប់ប្រាយ។

គន្ធ័នឆ្លើយថា ខ្ញុំបាទលីលា សួរមកពីនាយ
មិនមានគេដឹង ដំណឹងសព្វសាយ ខ្ញុំនិម្មិតកាយ
ជ្រែករោមគ្រុឌា។

ឯមហាក្សត្រថ្លៃ ពុំព្រួយព្រះទ័យ នឹងអ្នកទេណា៎
ខ្ញុំបាទអាណិត មានចិត្តមេត្តា ខែងខំយាត្រា
មកមិនគិតក្រែង។

ជាហេតុបុណ្យខ្ញុំ- បាទបានសូមសម អំពីព្រឹទ្ធព្រេង
នាំមកពើបពះ ប្រទះអ្នកឯង អរណាស់ឥតថ្លែង
ឥតបើថ្លឹងបាន។

នាងស្ដាប់ពាក្យកៀស ពាក្យកលបញ្ចៀស បញ្ចូលចង់ប្រាណ
ថាចាសអរហោង ដោយបងគិតធ្យាន សមបុណ្យបុរាណ
មែនពិតកន្លង។

បានបងឯងកូវ គ្រាន់បានជាផ្លូវ នាំអាថ៌ទំនង
ទៅទូលក្សត្រា ដោយនាហេតុផង សមអរនឹងបង
នឹងបានគុណគាប់។

នាងធ្វើជាស្ទោះ គន្ធ័នព្យច្ឆោះ វាងវៃឆ្លើយឆាប់
សង្វាតតាមមក រួសរកស្មើរស្លាប់ ស្រាប់តែក្រឡាប់
គ្មានគុណសោះសា។

សង្ឃឹមបានដល់ នឹងបានដូចកល ដូចចិត្តប្រាថ្នា
ឥឡូវអ្នកចេះ វិលវេះវាងថា ឱ្យមហាក្សត្រា
សងគុណឯនាយ។

ឯអ្នកបុណ្យស្គល់ ទៀងទេពុំយល់ គុណគេខ្វល់ខ្វាយ
សង្វាតតាមដិត ពុំគិតក្រងាយ គួរអ្នកនៅអោយ
ដឹងគុណតិចរ៉ា។

នាងស្ដាប់ពាក្យកើច ឱនអស់សំណើច សំណេះថ្លែងថា
ឱងប្អូនស្រី មានអ្វីថ្លៃថ្លា ឱ្យគាប់គួរជា
គន្ធ័នបងអរ។

គន្ធ័នឆ្លើយឆ្លៀត ឆ្លើយឆ្លាស់ទៅទៀត អុញនែមើលហ្ន៎
តែធនធានគ្មាន គង់មានព្រទ្យល្អ អ្នកពុំនឹករក៎
ឱ្យឯងពុំថា។

ទើបនាងឆ្លើយថ្កាន បងអើយប្អូនមាន តែខ្លួនទេណា៎
នឹងនៅជាខ្ញុំ ក្រែងពុំប្រាថ្នា ហេតុនេះបានជា
ប្អូនថាពុំមាន។

គន្ធ័នសើចសង ញញឹមឆ្លើយស្នង ថាបាទសូមទាន
តែត្រង់ណោះឯង គិតក្រែងបើបាន អរលើសធនធាន
អ្វីៗជាម្ដង។

នាងធ្វើជាស្ទោះ ថាបើប៉ុណ្ណោះ បានទេណា៎បង
ប្អូនខ្លាចបងចង់ បានត្រង់ទ្រព្យផង នោះនឹងរកសង
គុណគាប់ក្រក្រី។

គន្ធ័នព្រច្នោះ ព្រួចចិត្តចាប់ចោះ ចងចាប់មេត្រី
ខិតខាងចូលជិត នែបនិត្យកាយី ឱបអង្គកាកី
មិចម្មួលថើបថៃ។

នាងព្រួចព្រើសចិត្ត ចងចាប់ប្រតិព័ទ្ធ គីមោះប៉ុន្តែ
ការកេរ្តិ៍ខ្មាសស្រី ថាយីមើលនែ អញពុំស្និទ្ធស្នេហ៍
ប្រុសអ្វីដូច្នោះ។

អញស្មានថាស្មោះ ថាទៅប៉ុណ្ណោះ ស្រាប់តែវិលវេះ
ប្រលោមប្រលែង អញឯងងណេះ ហ៊ានហួសម្តេចម៉្លេះ
អញពុំដែលយល់។

មាត់តែជជែក ប្រកួតប្រកែក ដោយមាយាកល
ឯប្រាណប្រុសព្រម ល្ងាក់ល្ងមមណ្ឌល ពុំគិតអំពល់
អំពើក្រែងក្រ។

*****




## បទភុជង្គលីលា

ក្រោយគ្រុឌលាផុតទៅថ្កាន ព្រះមហាក្សត្រក្សាន្ត យល់គន្ធព្វា។
ដល់ស្រេចទើបស្តេចត្រាស់ថា បងចរលីលា ទៅរកកាកី។
ព្រាងដឹងដំណឹងឬអ្វី គន្ធ័នទូលខ្មី ថាទូលបង្គន់។
ស្វែងស្វះលាកលះតំបន់ ទៅឃើញនៅម- ណ្ឌលទាល់សិម្ពលី។
សត្វគ្រុឌវាពង្រត់ក្សត្រី ទៅសេពបេតី រួមរស់មណ្ឌល។
ទូលបង្គន់រង់មើលកល ឯអ្នកនាងយល់ ដណ្តឹងមកខ្មី។
ទូលបង្គន់គិតស្រដី បង្វែងសេចក្តី ចង់ដឹងកិរិយា។
ជាសុខឬទុក្ខម្តេចម្តា គិតមហាក្សត្រា ឬសោះសូន្យហើយ។

ឃើញជាក់ជាអ្នកកន្តើយ គ្មានទុក្ខសោកឡើយ ពព្រើតពព្រាយ។
ចូលជិតហាក់ស្និទ្ធនិយាយ ធ្វើកលនាយអាយ នឹងទូលបង្គន់។
យល់ប្លែកចម្លែកឡែបលន់ វាលើសខ្នាតស៊ិន ពុំកោតពុំក្រែង។
ឱ្យការចរចាចាយចែង ទូលបង្គន់ស្វែង ក្នុងចិត្តថាឃើ។
អ្នកនេះដល់ម៉្លេះមិញតើ ឯម៉្លេះថាបើ វិលមកបុរី។
ទំនងជាល្អងធូលី ព្រះបាទពុំភី- រម្យរួមស្នេហ៍ស្នង។
ដ្បិតគ្រុឌពង្រត់ទៅគ្រង រួមរស់កន្លង ជាពីរអង្គហើយ។
ហើយច្បាប់ទម្លាប់មុនឡើយ មហេសីត្រាណត្រើយ ពុំដែលដូច្នេះ។
គិតយល់ដូចកលទូលនេះ បានជាហ៊ានម៉្លេះ លលេងទល់ស៊ិន។
ពុំបានទូលថ្កានជាមុន ដល់ស៊ិនក្រលន់ ពុំចេរប្រោសប្រាណ។
ព្រះបាទនរនាថក្សត្រក្សាន្ត ស្តាប់គន្ធនបាន ទូលហើយក្សត្រថ្លៃ។
ត្រាស់កាន់គន្ធនថាហៃ បងកុំសង្ស័យ កុំភិតភយា។
អញក៏ពុំយកទោសា កុំបីបងបា- រម្ភរិះខ្លាចឡើយ។
សោកថ្វីមេស្រីកន្តើយ វាម៉្លោះអស់ហើយ នរណានឹងរាប់។
លើបងឯងហោងបងស្រាប់ អញពុំក្រឡាប់ យកគុណជាទោស។
ម្តេចៗគង់គេចចោលប្រោស ប្រុងតែសន្តោស ពុំគិតច្នោះច្នេះ។
ខឹងថ្វីសេចក្តីប៉ុណ្ណេះ ទោះលើសពីនេះ ក៏អញពុំខឹង។
ចូរបងត្រិះត្រងជញ្ជឹង ធ្វើកលម្តេចនឹង បានមកវិញណា។
កុំឱ្យដូចដោយចិត្តវា ពង្រាត់ពីគ្នា គ្រាន់មើលមុខលេង។

**កវីរាជ ព្រះហរិរក្សរាមាឥស្សរាធិបតី ព្រះអង្គដួង**

